## ២-សេចក្តីសំរេច

រាជធានីភ្នំពេញ,ថ្ងៃទី១៧ ខែតុលា ឆ្នាំ១៩៩៩

### សេចក្តីសំរេចលេខ ៤២ សសរ
### ស្តីពីការបង្កើតគណៈកម្មការសំរាប់ពិនិត្យ និង
### ដោះស្រាយបាតុភាពបញ្ហាដី នៅខេត្តកំពង់ស្ពឺ

***

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- យោងតាមការចាំបាច់ និងបន្ទាន់របស់រាជរដ្ឋាភិបាល

**សំរេច**

**ប្រការ ១ ៖** បង្កើតគណៈកម្មការសំរាប់ដោះស្រាយបាតុភាពបញ្ហាដី នៅស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ ដែលមានសមាសភាពដូចខាងក្រោម ៖

| | |
|---|---|
| ១-ឯកឧត្តម ឧត្តមសេនីយ៍ទោ កែវ តាំ ប្រធានអធិការកិច្ច ក្រសួងការពារជាតិ | ប្រធាន |
| ២-ឯកឧត្តម យឹម សុខុម អភិបាលរងទី ១ ខេត្តកំពង់ស្ពឺ | អនុប្រធាន |
| ៣-ឯកឧត្តម ឧត្តមសេនីយ៍ទោ នុំ សំបុល ប្រធានអធិការកិច្ច អគ្គសេនាធិការ ក.ឃ.ខ.ភ.ម | អនុប្រធាន |
| ៤-ឯកឧត្តម ឧត្តមសេនីយ៍ទោ សរិន ឌី មេបញ្ជាការរង កងទ័ពជើងគោក | សមាជិក |
| ៥-ឯកឧត្តម ម៉ៃ ចាន់រិទ្ធ អគ្គនាយករង ក្រសួងទំនាក់ទំនងសភា និង អធិការកិច្ច | សមាជិក |
| ៦-ឯកឧត្តម ឧត្តមសេនីយ៍ទោ ឡាញ់ ចៅ មេបញ្ជាការកងរថក្រោះ នៃអគ្គបញ្ជាការ | សមាជិក |
| ៧-លោក នុល ទីរទ្យ ប្រធានអធិការដ្ឋាន កិច្ចការនយោបាយ រដ្ឋបាល ក្រសួងមហាផ្ទៃ | សមាជិក |
| ៨-លោក សួន ស៊ីផាត ប្រធានការិយាល័យ ត្រួតពិនិត្យនៃនាយកដ្ឋានសុរិយោដី ក្រសួងរៀបចំដែនដីនគរូបនីយកម្មនិងសំណង់ ................................................ | សមាជិក |

៩-លោក សំឡូ ខុង អភិបាលស្រុក ភ្នំស្រួច .................................... សមាជិក

១០-លោក នខ ម្ទូ មេឃុំ តាំងស្យា .................................... សមាជិក

១១-លោក ឆាន់ ឈឿន តំណាងប្រជាជនភូមិក្លែកពង .................................... សមាជិក

១២-លោក ហែម ឆាយ តំណាងប្រជាជនភូមិក្លែកពង .................................... សមាជិក

**ប្រការ ២ :** គណៈកម្មការនេះ មានភារកិច្ច ៖

-ចុះស្រាវជ្រាវ និងលើកវិធានការដោះស្រាយអោយមានប្រសិទ្ធភាពនូវរាល់បាតុភាព ដែលកើតឡើង នៅតំបន់ អា.គេ.អូ ( មជ្ឈមណ្ឌលបាញ់ចំរុះស្វ័យប្រវត្តិ ) ស្ថិតនៅក្នុង ឃុំតាំងស្យា ស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ និងបន្តស្រាវជ្រាវលើកវិធានការ ដោះស្រាយបាតុភាពបញ្ហាដី នៅកន្លែងផ្សេងៗទៀត ក្នុងខេត្ត កំពង់ស្ពឺ ។

-ធ្វើរបាយការណ៍អំពីលទ្ធផលដោះស្រាយបាន ក្នុងករណីសុគស្មាញត្រូវលើកជូនរាជរដ្ឋាភិបាល សំរេច ។

**ប្រការ ៣ :** សមាជិកនៃគណៈកម្មការទាំងអស់ត្រូវចូលរួមប្រជុំ តាមការអញ្ជើញរបស់ប្រធាន ។

-គណៈកម្មការនេះ មានសិទ្ធិប្រើប្រាស់ត្រា របស់ក្រសួងការពារជាតិ ដើម្បីសំរួលការងារ ។

**ប្រការ ៤ :** បទបញ្ញត្តិទាំងឡាយណា ដែលផ្ទុយពីសេចក្តីសំរេចនេះ ត្រូវទុកជានិរាករណ៍ ។

**ប្រការ ៥ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងការពារជាតិ សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ អគ្គបញ្ជាការកងយោធពលខេមរភូមិន្ទ រដ្ឋមន្ត្រីក្រសួងទំនាក់ទំនងសភានិងអធិការកិច្ច រដ្ឋមន្ត្រីក្រសួង រៀបចំដែនដីនគរូបនីយកម្ម និង សំណង់ រដ្ឋមន្ត្រី រដ្ឋលេខាធិការនៃក្រសួង ស្ថាប័នពាក់ព័ន្ធ អភិបាល ខេត្តកំពង់ស្ពឺ និង ឯកឧត្តមអស់លោក ដែលមានឈ្មោះក្នុងប្រការ១ ត្រូវទទួលបន្ទុកអនុវត្តសេចក្តី សំរេចនេះ ឲ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ជ.នាយករដ្ឋមន្ត្រី

ឧបនាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

ស ខេង

***